Disability Rights California

*គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា*
*ទូរសព្ទហៅឥតគិតថ្លៃ (800) 776-5746*

# សិទ្ធិទទួលបានអត្ថប្រយោជន៍តំហែទាំសុខភាពទាន់ពេលវេលា

***ខែឧសភា ឆ្នាំ 2016 ការបោះពុម្ពផ្សាយ 5556.06***

ច្បាប់រដ្ឋកាលីហ្វ័រញ៉ា និយាយថា គម្រោងគ្រប់គ្រងសេវាតំហែទាំសុខភាពត្រូវតែធ្វើឲ្យប្រាកដប្រជាថា អ្នកបានទទួលសិទ្ធិប្រើប្រាស់សេវាតំហែទាំសុខភាពក្នុងលក្ខណៈទាន់ពេលវេលា។[1] ខាងក្រោមនេះ គឺជាក្របខណ្ឌពេលវេលាសម្រាប់ការទទួលបានសេវាតំហែទាំព្យាបាល:

## ប្រភេទនៃការណាត់ជួប & ក្របខណ្ឌពេលវេលា

- ការណាត់ជួបដែលមិនមែនជាករណីបន្ទាន់ជាមួយនឹងវេជ្ជបណ្ឌិតតំហែទាំសុខភាពអ្នកក្នុងរយៈពេល 10 ថ្ងៃធ្វើការក្រោយការដាក់សំណើរបស់អ្នក។*
- ការណាត់ជួបដែលមិនមែនជាករណីបន្ទាន់ជាមួយនឹងគ្រូពេទ្យឯកទេសក្នុងរយៈពេល 15 ថ្ងៃធ្វើការក្រោយការដាក់សំណើរបស់អ្នក។*
- ការណាត់ជួបដែលមិនមែនជាករណីបន្ទាន់សម្រាប់សេវាបន្ទាប់បន្សំ (ការថតកាំរស្មីអ៊ិច...ជាដើម) ដើម្បីធ្វើរោគវិនិច្ឆ័យ ឬព្យាបាលរបួស ជម្ងឺ ឬលក្ខខណ្ឌសុខភាពផ្សេងទៀតក្នុងរយៈពេល 15 ថ្ងៃធ្វើការក្រោយការដាក់សំណើរបស់អ្នក។*
- ការណាត់ជួបដែលមិនមែនជាករណីបន្ទាន់ជាមួយនឹងអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តដែលមិនមែនជាគ្រូពេទ្យក្នុងរយៈពេល 10 ថ្ងៃធ្វើការក្រោយការដាក់សំណើរបស់អ្នក។*
- ការណាត់ជួបដែលជាករណីបន្ទាន់ដែលមិនចាំបាច់ត្រូវការការឯកភាពជាមុន ក្នុងរយៈពេល 48 ថ្ងៃធ្វើការក្រោយការដាក់សំណើរបស់អ្នក។

---

[1] ផ្នែកទី 1367.03 នៃក្រមច្បាប់សុខភាព និងសុវត្ថិភាពនៃរដ្ឋកាលីហ្វ័រញ៉ា។ ចំណងជើងទី 28 នៃបញ្ញត្តិច្បាប់រដ្ឋកាលីហ្វ័រញ៉ា (ផ្នែក 1300.67.2.2)។ បញ្ញត្តិច្បាប់ទាំងនេះ ក៏មានរួមបញ្ចូលផងដែរនូវការពិនិត្យភ្នែក ធ្មេញ និងតំហែទាំព្យាបាលផ្សេងទៀតដែរ។ លើសពីនេះ មើលទំព័រតាមតំណ http://wpso.dmhc.ca.gov/regulations/docs/13CCRP.pdf។

– ការណាត់ជួបដែលជាករណីបន្ទាន់ដែលចាំបាច់ត្រូវមានការឯកភាពជាមុន ក្នុងរយៈពេល 96 ថ្ងៃធ្វើការក្រោយការដាក់សំណើរបស់អ្នក។

## ពេលរង់ចាំទូរសព្ទ

សិទ្ធិហៅទូរសព្ទ 24 ម៉ោងក្នុងមួយថ្ងៃ (7 ថ្ងៃក្នុងមួយសប្តាហ៍) ដើម្បីនិយាយជាមួយនឹងគ្រូពេទ្យអាជីពផ្នែកសុខភាពដើម្បីកំណត់កម្រិតអាទិភាពនៃតម្រូវការសេវាវេជ្ជសាស្ត្ររបស់អ្នក។ រយៈពេលរង់ចាំមិនអាចលើសពី 30 នាទីបានទេ។

ហៅទូរសព្ទទាក់ទងទៅផ្នែកអតិថិជននៅក្នុងម៉ោងធ្វើការធម្មតា។ រយៈពេលរង់ចាំមិនអាចលើសពី 10 នាទីបានទេ។

## ការលើកលែង

*ការថែទាំព្យាបាលបង្ការ និងការថែទាំព្យាបាលតាមដានជម្ងឺតាមរបបទៀងកំណត់ពេល។

*អាចមានការពន្យាពេលរង់ចាំសម្រាប់ការណាត់ជួបបាន បើគ្រូពេទ្យតំហែទាំសុខភាពអ្នកកំណត់ ឬបញ្ជាក់ថា រយៈពេលរង់ចាំកាន់តែយូរនឹងមិនមានអន្តរាយដល់សុខភាពអ្នក។

វេជ្ជបណ្ឌិតតំហែទាំសុខភាពបឋមរបស់អ្នក អាចស្នើឲ្យអ្នកណាត់ជួបជាមួយនឹងវេជ្ជបណ្ឌិតតំហែទាំសុខភាព អ្នកហ្វឹកហាត់ជំនាញគិលានុប្បដ្ឋាក ឬជំនួយការគ្រូពេទ្យម្នាក់នៅថ្ងៃដដែល ឬបន្ទាប់ដោយរាប់ចាប់ពីពេលដែលអ្នកស្នើសុំការណាត់ជួបមួយបាន។ នេះគេហៅថាៈ “សិទ្ធិកម្រិតខ្ពស់”។ បើអ្នកមិនចង់ឲ្យមានការណាត់ជួបនេះទេ នឹងមានការដាក់កំណត់ការណាត់ជួបរបស់អ្នកនៅកាលបរិច្ឆេទក្រោយទៀត។

តើវានឹងយ៉ាងដូចម្តេចដែរ ក្នុងករណីដែលគ្មានអ្នកផ្តល់សេវា ឬគ្រូពេទ្យគ្រប់គ្រាន់នៅតាមតំបន់អ្នក?

ច្បាប់នេះនិយាយថា បើក្នុងករណីដែលអ្នកមិនអាចទទួលបានការណាត់ជួបទាន់ពេលវេលានៅតាមតំបន់របស់អ្នកដោយសារតែគ្មានអ្នកផ្តល់សេវាកម្ម ឬគ្រូពេទ្យគ្រប់គ្រាន់ទេនោះ ពេលនោះគម្រោងសុខភាពរបស់អ្នកត្រូវតែជួយឲ្យអ្នកមានការណាត់ជួបជាមួយនឹងប្រភេទអ្នកផ្តល់សេវា ឬគ្រូពេទ្យដែលត្រឹមត្រូវ។

អ្វីដែលអ្នកអាចនឹងធ្វើបាន ក្នុងករណីដែលអ្នកមិនទទួលបានសិទ្ធិប្រើប្រាស់សេវាកម្មទាន់ពេលវេលា:

1. ប្តឹងតវ៉ាទៅគម្រោងសុខភាពរបស់អ្នក។
2. ដាក់ពាក្យបណ្តឹងតាមរយៈការហៅទៅបណ្តាញទូរសព្ទជំនួយ (ទូរសព្ទឥតគិតថ្លៃ) នៅផ្នែកគ្រប់គ្រងសេវាតំហែទាំសុខភាពដែលមានលេខ (888) 466-2219, TDD: (877) 688-9891 ឬ http://www.dmhc.ca.gov/fileacomplaint.aspx#.Vvlk6tIrKUk
3. ហៅទៅបណ្តាញទូរសព្ទជំនួយ (ទូរសព្ទឥតគិតថ្លៃ) របស់គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ាដែលមានលេខ (800) 776-5746, TTY (800) 719-5798 ឬវិបសាយដែលមានអាសយដ្ឋាន http://www.disabilityrightsca.org

យើងខ្ញុំចង់ស្តាប់ឮពីអ្នក! សូមមេត្តាបំពេញទម្រង់បែបបទស្ទង់មតិខាងក្រោមដែលស្តីពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ ហើយនិងអនុញ្ញាតឲ្យយើងខ្ញុំបានដឹងអំពីរបៀបដែលកំពុងតែអនុវត្ត! https://docs.google.com/forms/d/1d6ezTl2M5UMAWU66exLbc1SQ9wDPzvtuS3AGR4-cgwE/viewform?c=0&w=1

*គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ាទទួលបានការឧបត្ថម្ភថវិកាពីប្រភពជាច្រើន សម្រាប់បញ្ជីអ្នកឧបត្ថម្ភថវិកាពេញលេញ ឆ្ពោះទៅកាន់ទំព័រដែលមានតំណ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html.